AMNESTY INTERNATIONAL

AI Index: ASA 23/9150/2018
ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៨

# សេចក្ដីថ្លែងការណ៍ផ្ទាល់មាត់
# ចំណុចទី១០ ៖ កិច្ចសន្ទនាផ្ទាល់ជាមួយអ្នករាយការណ៍ពិសេសស្ដីពីបញ្ហាកម្ពុជា
# ការបញ្ចប់ការគំរាមកំហែង ការឃុំឃាំង និងបណ្ដឹងសាធារណៈប្រឆាំងនឹងសកម្មជន អ្នកកាសែត និងអ្នកការពារសិទ្ធិមនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជា

ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ
សម័យប្រជុំលើកទីសាមសិបប្រាំបួន
ថ្ងៃទី១០-២៨ ខែកញ្ញា ឆ្នាំ២០១៨

លោកប្រធានជាទីគោរព!

អង្គការលើកលែងទោសអន្តរជាតិសូមចូលរួមចំណែកបង្ហាញនូវការព្រួយបារម្ភរបស់អ្នករាយការណ៍ពិសេសអំពីការបន្តការវាយប្រហារដោយឥតលាក់លៀមដោយរដ្ឋាភិបាលកម្ពុជាលើសិទ្ធិសេរីភាពចូលរួមសមាគម ខាងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី។

ក្នុងអំឡុងពេលមុនបោះឆ្នោត អាជ្ញាធរកម្ពុជាបានគំរាមកំហែង ឃាត់ខ្លួន និងចោទប្រកាន់សកម្មជន អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រឆាំងនានា ជុំវិញការចោទប្រកាន់មិនត្រឹមត្រូវចំពោះការងារសិទ្ធិមនុស្សរបស់ពួកគេ ឬគ្រាន់តែសម្រាប់មតិខុសគ្នា។

យើងទទួលស្គាល់ការពិតដែលថា អ្នកទោសចំនួន២០នាក់ ត្រូវបានដោះលែងចាប់តាំងពីការបោះឆ្នោតជាតិនៅខែកក្កដាហើយ។ ក៏ប៉ុន្តែ ដោយភាគច្រើននៃអ្នកដែលត្រូវបានដោះលែង នៅតែជាប់ចោទពីបទព្រហ្មទណ្ឌ និងការកាត់ទោសដែលគេអាចបន្តឡើងវិញពេលណាក៏បាន។ ហ៊ុនសែន ផ្ទាល់បានព្រមានអ្នករិះគន់របស់គាត់ឱ្យនៅស្ងាត់ស្ងៀម។

ការបិទស្ថានីយវិទ្យុជាង ៣០ នៅក្នុងឆ្នាំ២០១៧ សម្រាប់ការផ្សព្វផ្សាយព័ត៌មានឯករាជ្យ បន្តរាំងសាធារណជនពីការទទួលបានព័ត៌មានពីប្រភពផ្សេងៗ។ ការបង្ក្រាបលើវេទិកាព័ត៌មានសង្គម បានធ្វើឱ្យបុគ្គលជាច្រើនទទួលរងបទចោទប្រកាន់ក្លែងក្លាយ ចំពោះការប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិរបស់ពួកគេ។

អង្គការលើកលែងទោសអន្តរជាតិ ក៏សូមចូលរួមចំណែកបង្ហាញនូវការព្រួយបារម្ភរបស់អ្នករាយការណ៍ពិសេស លើការការចោទប្រកាន់ខាងផ្លូវច្បាប់បែបឃោរឃៅផ្ដាច់ការដែលគេបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ ទាំងនេះរួមបញ្ចូលទាំងការដូរច្បាប់គណបក្សនយោបាយ ដើម្បីផ្ដល់អំណាចតុលាការធ្វើតាមអំពើចិត្ត ក្នុងរំលាយគណបក្ស និងការដូរច្បាប់សហជីព ឱ្យមានប្រសិទ្ធិភាពដាក់កូដកម្មរបស់កម្មករជាបទល្មើសព្រហ្មទណ្ឌ។ ច្បាប់ដែលគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល ក៏ផ្ដល់ឱ្យក្រសួងមហាផ្ទៃនូវអំណាចស្រដៀងគ្នាទៅលើសង្គមស៊ីវិលផងដែរ "ដែលនាំឱ្យមានការត្រួតពិនិត្យរកចាប់ពិរុទ្ធលើខ្លួនឯងដោយអង្គការជាច្រើន។" ច្បាប់ទាំងនេះបង្កើតជាការគំរាមកំហែងកាន់តែកើនឡើងលើអ្វីដែលនៅសេសសល់នៃសង្គមស៊ីវិល។

អង្គការលើកលែងទោសអន្តរជាតិ សូមអំពាវនាវឱ្យសហគមន៍អន្តរជាតិចាត់វិធានការជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាបន្ទាបបន្ថោកលើស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ សហគមន៍អន្តរជាតិត្រូវតែអំពាវនាវដល់ឲ្យរដ្ឋាភិបាលកម្ពុជាដោះលែងអ្នកទោសមនសិការទាំងអស់ជាបន្ទាន់ ដកចេញនូវការចោទប្រកាន់និងការផ្តន្ទាទោសទាំងអស់ ប្រឆាំងនឹងអ្នកដែលបានដោះលែងដោយគ្មានលក្ខខណ្ឌ បញ្ចប់ការបង្ក្រាបលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងកែប្រែ ឬលុបចោលច្បាប់ឃោរឃៅទាំងអស់នោះចេញ។

សូមអរគុណ